ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

ថ្ងៃចន្ទ ១៤ រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

លេខ: ៣៤២ អក.រដ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០២០

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែមេសា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត។

**ជូនភ្ជាប់** ៖-របាយការណ៍ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែមេសា ឆ្នាំ២០២០...........ចំនួន០១ច្បាប់

-តារាងស្ថានភាពផលិតកម្មកៅស៊ូ និងតារាងស្ថានភាពធុរកិច្ចផលិតផលកៅស៊ូស្ងួត ប្រចាំខែមេសា ឆ្នាំ២០២០ ........................................ចំនួន០២ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំខែមេសា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្តដោយសង្ខេបដូចខាងក្រោម៖

១-ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៤ ៨០១ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៥០ ០៦៦ហិកតា ស្មើនឹង៦២% និងផ្ទៃដីថែទាំមានចំនួន១៥៤ ៧៣៥ហិកតា ស្មើនឹង៣៨%។

២-ផលិតផលជ័រកៅស៊ូក្នុងខែមានចំនួន១៨ ៩៦១តោន កើនឡើងចំនួន៨ ១៣៧តោន ស្មើនឹង៧៥% ធៀបនឹងខែមុន និងបានកើនឡើងចំនួន៤ ៥៤១ ស្មើនឹង៣១%ធៀប រយៈពេលដូចគ្នាឆ្នាំមុន។ ផលិតផលជ័រកៅស៊ូមកដល់ខែនេះ មានចំនួន៧២ ២៣៣តោន បានកើនឡើងចំនួន៩ ៦៣០តោន ស្មើនឹង១៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៣-បរិមាណបញ្ចេញលក់ក្នុងខែមានចំនួន១៨ ៦០៤តោន កើនឡើងចំនួន៦ ៨៥៣តោន ស្មើនឹង៥៨% ធៀបនឹងខែមុននិងបានកើនឡើង៣ ៣២២តោនស្មើនឹង២២%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ បរិមាណបញ្ចេញលក់មកដល់ខែនេះមានចំនួន៧១ ៧៤៩តោន បានកើនឡើងចំនួន៨ ២៧៥តោន ស្មើនឹង១៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៤-តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែថ្លៃ១ ១៩២ដុល្លារ/តោន បានថយចុះចំនួន២០៥ដុល្លារ/តោនស្មើនឹង ១៤,៦៧%ធៀបនឹងខែមុន និងបានថយចុះ១៧៣ដុល្លារ/តោនស្មើនឹង១៣%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។តម្លៃលក់កៅស៊ូមធ្យមគិតដល់ខែនេះថ្លៃ១ ៣៥៨ដុល្លារ/តោន បានកើនឡើងចំនួន៥៩ដុល្លារ/តោន ស្មើនឹង៥%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៥-តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ៣០០-៤ ៧០០៛/គ.ក្រ (បានថយចុះ២៨៣៛/គ.ក្រ ស្មើនឹង ៥,៩% ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ១ ៧០០-១ ៩០០៛/គ.ក្រ បានថយចុះចំនួន៣៦០៛/គ.ក្រ ស្មើនឹង១៦,៨% ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

៦-ទិសដៅបន្ត៖ ខិតខំអនុវត្តទិសដៅការងារដែលបានគ្រោងទុកឲ្យបានសម្រេចលទ្ធផលល្អ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ចម្លងជូន៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក

"ដើម្បីជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់ចម្ការកៅស៊ូកសិឧស្សាហកម្ម

"ដើម្បីជ្រាប"
- ឯកសារ

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ប៉ុល សុផា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

# របាយការណ៍សរុប
# ស្តីពី
# ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំខែមេសា ឆ្នាំ២០២០
# និងទិសដៅអនុវត្តបន្ត

## ១.សេចក្តីផ្តើម

ក្នុងឆ្នាំ២០២០ នេះអគ្គនាយកដ្ឋានកៅស៊ូ បានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ទាំងការងារចរន្ត ការងារអនុវត្តគម្រោងថវិកាតាមកម្មវិធី ការងារជាំផុះ ថៃទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ច ទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងខែមេសា ឆ្នាំ២០២០ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

## ២.លទ្ធផលការងារសម្រេចបាន

### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

#### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៤ ៨០១ ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ២៥០ ០៦៦ហិកតា ស្មើនឹង៦២% និងផ្ទៃដីថែទាំមានចំនួន១៥៤ ៧៣៥ហិកតា ស្មើនឹង៣៨%។

#### ២.១.២ ផលិតកម្ម

- ផលិតផលជ័រកៅស៊ូសម្រេចបានប្រចាំខែមេសា ឆ្នាំ២០២០ មានចំនួន១៨ ៩៦១តោន បានកើនឡើងចំនួន៨ ១៣៧តោនស្មើនឹង៧៥%ធៀបនឹងខែមុននឹងបានកើនឡើងចំនួន៤ ៥៤១ស្មើនឹង៣១%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- ផលិតផលជ័រកៅស៊ូសរុបគិតមកដល់ខែមេសា ឆ្នាំ២០២០ សម្រេចបានចំនួន៧២ ២៣៣តោនបានកើនឡើងចំនួន៩ ៦៣០តោន ស្មើនឹង១៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

#### ២.១.៣ ធុរកិច្ចកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែមេសា ឆ្នាំ២០២០ មានចំនួន១៨ ៦០៤តោន បានកើនឡើងចំនួន៦ ៨៥៣តោន ស្មើនឹង៥៨%ធៀបនឹងខែមុននឹងបានកើនឡើងចំនួន៣ ៣២២តោនស្មើនឹង២២% ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- បរិមាណបញ្ចេញលក់សរុបគិតមកដល់ខែមេសា ឆ្នាំ២០២០ សម្រេចបានចំនួន៧១ ៧៤៩តោន កើនឡើងចំនួន៨ ២៧៥តោន ស្មើនឹង១៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់មធ្យមជ័រកៅស៊ូក្នុងខែមេសា ឆ្នាំ២០២០ មានចំនួន ១ ១៩២ដុល្លារ/តោន បានថយចុះចំនួន២០៥ដុល្លារ/តោន ស្មើនឹង១៤,៦៧%ធៀបនឹងខែមុន និងបានថយចុះចំនួន១៧៣ដុល្លារ/តោនស្មើនឹង១៣%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់កៅស៊ូជាមធ្យមគិតមកដល់ខែមេសា ឆ្នាំ២០២០ គឺ១ ៣៥៨ ដុល្លារ/តោន បានកើនឡើងចំនួន ៥៩ ដុល្លារ/តោន ស្មើនឹង៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ៣០០-៤ ៧០០រ/គ.ក្រ(បានថយចុះ២៨៣រ/គ.ក្រ ស្មើនឹង ៥,៩% ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ១ ៧០០-១ ៩០០រ/គ.ក្រ បានថយចុះចំនួន៣៦០រ/គ.ក្រ ស្មើនឹង១៦,៨% ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

## ២.២. ការងារចរន្តនិងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

### ២.២.១. ការងារចរន្ត

- ពិនិត្យនិងធ្វើបច្ចុប្បន្នភាពលើជំនួយស្មារតីក្នុងក្របខ័ណ្ឌសហប្រតិបត្តិការរបស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍(AFD)ជាមួយអគ្គនាយកដ្ឋានកៅស៊ូ
- ពិនិត្យនិងកែសម្រួលលើគម្រោងផែនការចំណាយថវិកាតាមកម្មវិធីរបស់នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូឆ្នាំ២០២០ លើសកម្មភាពចំនួន៤ ក្នុងនោះរួមមាន៖(១)បណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ (២)សិក្ខាសាលាផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូដល់មន្ត្រីបង្គោល (៣)ពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ (៤)ចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ
- រៀបចំបូកសរុបរបាយការណ៍តាមដាននិងវាយតម្លៃការអនុវត្តថវិកាកម្មវិធីប្រចាំត្រីមាសទី១(ទម្រង់ M1) និងរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តកម្មវិធី(តារាងទី២៤,២៥,២៦)ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានកៅស៊ូ
- រៀបចំធ្វើវិចារណកម្មថវិការបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំឆ្នាំ២០២០ ស្របតាមការណែនាំរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- រៀបចំនិងបូកសរុបផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០ បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មឆ្នាំ២០៣០
- ផ្សព្វផ្សាយពត៌មានអំពីថ្លៃកៅស៊ូនៅទីផ្សារក្នុងនិងក្រៅប្រទេសតាមវិទ្យុ ដើម្បីជំរុញថ្លៃលក់ជ័រកៅស៊ូឱ្យបានប្រសើរ
- បានប្រមូលទិន្នន័យ និងរៀបចំតម្លៃកៅស៊ូធម្មជាតិសម្រាប់ផ្សាយប្រចាំសប្តាហ៍តាមវិទ្យុមណ្ឌលព័ត៌មាន ស្ត្រីកម្ពុជា(FM103.5)ចំនួន០៤ដងក្នុងមួយខែ(១សប្តាហ៍១ដង) និងបានផ្សាយបន្តផ្ទាល់ទៅតាម បណ្តាខេត្តចំនួន៤ខេត្ត គឺខេត្តបាត់ដំបង(FM106.3) ខេត្តកំពង់ចាម(FM99.3) ខេត្តកំពង់ធំ(FM104) និង ខេត្តសៀមរាប(FM107) រៀងរាល់ថ្ងៃចន្ទ វេលាម៉ោង១០ព្រឹក។

### ២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី

ការចំណាយថវិកាក្នុងខែមេសា ឆ្នាំ២០២០ មានចំនួន ៨៩ ៣០៥ ៦១០រៀល។ បើគិតរហូតមកដល់ខែមេសានេះមានចំនួន៤៥៨ ០២៧ ៥១៨រៀល ស្មើនឹង២១,៥៤ ភាគរយនៃផែនការ។

### ២.២.៣. ការប្រមូលចំណូលថវិកា

ការប្រមូលចំណូលថ្លៃឈ្នួលដីអវិនិយោគចម្ការកៅស៊ូរដ្ឋទាំង៧ ចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគីរី និងក្រុមហ៊ុននីហាវ៉ណៃ អាហាវ៉ណៃកៅស៊ូក្នុងខែមេសា ឆ្នាំ២០២០ អនុវត្តបានចំនួន២០៨ ៧១២ ២៤២រៀល។ បើគិតរហូតមកដល់ខែមេសានេះអនុវត្តន៍បានចំនួន៥៦៤ ២៣១ ២០២រៀល ស្មើនឹង៣៦,០៣ភាគរយនៃផែនការ។

## ៣. ទិសដៅបន្ត

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកៅស៊ូ
- បន្តចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ

- បន្តចុះពង្រឹង និងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ
- បន្តចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តអនុវត្តគម្រោងផែនការសកម្មភាពថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២០
- រៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- បន្តរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូជាតិឆ្ពោះទៅឆ្នាំ២០៣០
- បន្តខិតខំធ្វើទំនាក់ទំនងកិច្ចសហប្រត្តិបត្តិការជាមួយដៃគូរអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ
- បន្តរៀបចំផែនការសកម្មភាពការងារសំណើគម្រោង និងទស្សនាទាននៃគម្រោងពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មកៅស៊ូជាតិ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូបានប្រគល់អោយ។

ថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២០

**ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម**

យួន ផល្លា

**បានឃើញនិងឯកភាព**

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**អគ្គនាយករង**

ចាន់ វឌ្ឍនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

តារាងទី២

## តារាងស្ថានភាពចុះកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែមេសា ឆ្នាំ២០២០

| ល.រ | ចម្ការកៅស៊ូ | មេសា ២០១៩ | | | | | | មេសា ២០២០ | | | | | | ធៀបខែមុន | | | | ធៀបរយៈពេលដូចគ្នានៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ | | តម្លៃមធ្យម | | បរិមាណ | | | | តម្លៃមធ្យម | | | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | | ខែនេះ | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | | | | | | | | | | | | | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| | I. កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 0 | 50 | 0 | 64.000 | 0 | 1.280 | | 15 | | 14.500 | 0 | 967 | 0 | 0 | 0 | 0 | 0 | 0 | -35 | -70 | 0 | 0 | -313 | -24 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 806 | 4.168 | 1.106.672 | 5.402.557 | 1.374 | 1.296 | 1.591 | 3.187 | 1.905.274 | 4.289.302 | 1.198 | 1.346 | 1.322 | 491,03 | -316 | -20,88 | 785 | 98 | -981 | -24 | -176 | -13 | 50 | 4 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 0 | 336 | 0 | 432.600 | 0 | 1.288 | | 210 | | 275.940 | 0 | 1.314 | 0 | 0 | 0 | 0 | 0 | 0 | -126 | -38 | 0 | 0 | 27 | 2 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 260 | 1.215 | 356.900 | 1.607.236 | 1.373 | 1.323 | | 994 | | 1.539.406 | 0 | 1.549 | -197 | 0,00 | -1.585 | 0,00 | -260 | 0 | -221 | -18 | 0 | 0 | 226 | 17 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 21 | 21 | 24.149 | 24.149 | 1.150 | 1.150 | | 88 | | 101.574 | 0 | 1.161 | 0 | 0 | 0 | 0 | -21 | 0 | 67 | 317 | 0 | 0 | 11 | 1 |
| 6 | ក្រុមហ៊ុនស៊ីហ្វ វីសសស៍ លីមីធីត(ស្នួល) | 0 | 800 | 0 | 956.728 | 0 | 1.197 | 543 | 1.737 | 650.500 | 2.257.680 | 1.198 | 1.300 | 293 | 117,55 | -102 | -7,85 | 543 | 100 | 938 | 117 | 1.198 | 100 | 103 | 9 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 882 | 1.302 | 1.227.135 | 1.796.865 | 1.391 | 1.380 | | 925 | | 1.315.125 | 0 | 1.422 | 0 | 0,00 | 0 | 0,00 | -882 | 0 | -377 | -29 | 0 | 0 | 42 | 3 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 228 | 533 | 283.694 | 629.094 | 1.245 | 1.181 | 120 | 500 | 133.100 | 605.200 | 1.109 | 1.210 | -30 | -20,00 | -128 | -10,31 | -108 | -47 | -33 | -6 | -136 | -11 | 30 | 3 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | 65 | 260 | 80.196 | 315.096 | 1.230 | 1.211 | 50 | 239 | 57.500 | 288.624 | 1.150 | 1.209 | -10 | -16,94 | -58 | -4,78 | -15 | -23 | -21 | -8 | -80 | -7 | -2 | 0 |
| 10 | ក្រុមហ៊ុនក្រេក(ខេមបូឌា) ខូអិលធីឌី | 420 | 1.890 | 580.440 | 2.466.870 | 1.382 | 1.305 | | 1.155 | | 1.600.200 | 0 | 1.385 | -525 | 0,00 | -1.380 | 0,00 | -420 | 0 | -735 | -39 | 0 | 0 | 80 | 6 |
| | **សរុប ក** | **2.682** | **10.574** | **3.659.186** | **13.695.195** | **1.365** | **1.295** | **2.304** | **9.049** | **2.746.374** | **12.287.551** | **1.192** | **1.358** | **853** | **58,81** | **-205** | **-14,67** | **-378** | **-14** | **-1.525** | **-14** | **-173** | **-13** | **63** | **5** |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 5.100 | 21.200 | 6.959.325 | 27.576.614 | 1.365 | 1.301 | 6.900 | 26.300 | 8.224.674 | 35.700.824 | 1.192 | 1.357 | 2.500 | 56,82 | -205 | -14,67 | 1.800 | 35 | 5.100 | 24 | -173 | -13 | 57 | 4 |
| | សរុបI=ក+ខ | 7.782 | 31.774 | 10.618.510 | 41.271.809 | 1.365 | 1.299 | 9.204 | 35.349 | 10.971.047 | 47.988.375 | 1.192 | 1.358 | 3.353 | 57,31 | -205 | -14,67 | 1.422 | 18 | 3.575 | 11 | -173 | -13 | 59 | 5 |
| | II. កៅស៊ូគ្រួសារ | 7.500 | 31.700 | 10.234.301 | 41.214.803 | 1.365 | 1.300 | 9.400 | 36.400 | 11.204.628 | 49.452.808 | 1.192 | 1.359 | 3.500 | 59,32 | -205 | -14,67 | 1.900 | 25 | 4.700 | 15 | -173 | -13 | 58 | 4 |
| | **សរុបI+II** | **15.282** | **63.474** | **20.852.811** | **82.486.612** | **1.365** | **1.300** | **18.604** | **71.749** | **22.175.675** | **97.441.183** | **1.192** | **1.358** | **6.853** | **58,32** | **-205** | **-14,67** | **3.322** | **22** | **8.275** | **13** | **-173** | **-13** | **59** | **5** |

**បញ្ជាក់៖**

១. ក្នុងខែមេសា ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន១៨ ៦០៤តោន បានកើនឡើង៦ ៨៥៣តោន(=+៥៨,៣២%)បើធៀបនឹងខែមុន និងបានកើនឡើង៣ ៣២២តោន(=+២២%)បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

២. ក្នុងខែមេសា ឆ្នាំ២០២០ តម្លៃលក់មធ្យមគឺ១ ១៩២ដុល្លារ/តោន បានថយចុះចំនួន២០៥ដុល្លារ/តោន(=-១៤,៦៧%)ធៀបនឹងខែមុន និងបានថយចុះ១៧៣ដុល្លារ/តោន(=-១៣%)បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

៣. រហូតមកដល់ខែមេសា ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន៧១ ៧៤៩តោន បានកើនឡើង៨ ២៧៥តោន(=+១៣%)ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៩។

៤. រហូតដល់ខែមេសា ឆ្នាំ២០២០ តម្លៃលក់មធ្យមគឺ១ ៣៥៨ដុល្លារ/តោន បានកើនឡើងចំនួន៥៩ដុល្លារ/តោន(=+៥%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

ថ្ងៃពុធ ១២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០
អ្នកធ្វើតារាង

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង
យុន ភក្តា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ
ហ៊ិន-សារិន

អគ្គនាយកដ្ឋានកៅស៊ូ

នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

ជាតិ សាសនា ព្រះមហាក្សត្រ

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែមេសា ឆ្នាំ២០២០

តារាងទី១

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០១៩ | | | | សន្និធិដើមឆ្នាំ | ឆ្នាំ២០២០ | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | ចៀរជ័រ | ថែទាំ | សរុប | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ផ្ទៃដីសរុប | | ផលិតផល | | បញ្ចេញលក់ | | ផលិតផល | | | | បញ្ចេញលក់ | | | | |
| | | | | | | | | | | | | | | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 670 | 132 | 801 | 26 | 121 | | 50 | 158 | 24 | 86 | - | 15 | 0 | 0 | 11 | 78 | 0 | 0 | -1 | -5 | -36 | -29 | 0 | 0 | -35 | -70 | 229 |
| 2 | ក្រុមហ៊ុនសុគន្ធីកា អ៊ីនវេសមេន គ្រុប | 11.287 | 3.262 | 14.549 | 923 | 3.489 | 806 | 4.168 | 1.093 | 1.297 | 3.925 | 1.591 | 3.187 | -684 | -4 | 967 | 293 | 1.322 | 491 | 374 | 41 | 436 | 12 | 785 | 98 | -981 | -24 | 1.832 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1.118 | 1.247 | 2.365 | 79 | 355 | - | 336 | 21 | 62 | 281 | - | 210 | 0 | 0 | 62 | 100 | 0 | 0 | -17 | -22 | -74 | -21 | 0 | 0 | -126 | -38 | 92 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខុអិលធីឌី | 6.103 | 1.912 | 8.015 | 91 | 806 | 260 | 1.215 | 618 | 162 | 828 | - | 994 | 0 | 0 | 145 | 852 | -197 | 0 | 71 | 78 | 21 | 3 | -260 | 0 | -221 | -18 | 452 |
| 5 | ក្រុមហ៊ុនស៊ីហ្វូ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 306 | 2.418 | 2.724 | 18 | 34 | 21 | 21 | 365 | 19 | 75 | - | 88 | 0 | 0 | 11 | 141 | 0 | 0 | 1 | 6 | 40 | 117 | -21 | 0 | 67 | 317 | 352 |
| 6 | ក្រុមហ៊ុនស៊ីហ្វូ វីសសស់ លីមីធីត(ស្នួល) | 4.174 | 76 | 4.250 | 105 | 665 | - | 800 | 2.248 | 187 | 563 | 543 | 1.737 | 0 | 0 | 187 | 100 | 293 | 118 | 83 | 79 | -102 | -15 | 543 | 100 | 938 | 117 | 1.074 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ិនធើណេស៊ិនណល | 3.908 | 278 | 4.186 | - | 567 | 882 | 1.302 | 756 | 46 | 460 | - | 925 | 0 | 0 | 46 | 100 | 0 | 0 | 46 | 100 | -107 | -19 | -882 | 0 | -377 | -29 | 291 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្ដូង) | 3.312 | 1.570 | 4.882 | 106 | 347 | 228 | 533 | 613 | 84 | 265 | 120 | 500 | 0 | 0 | 40 | 91 | -30 | -20 | -22 | -21 | -82 | -24 | -108 | -47 | -33 | -6 | 378 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង+រមាសហែក) | 1.918 | 1.119 | 3.037 | 73 | 192 | 65 | 260 | 380 | 46 | 173 | 50 | 239 | 0 | 0 | 34 | 296 | -10 | -17 | -27 | -37 | -20 | -10 | -15 | -23 | -21 | -8 | 314 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខុអិលធីឌី | 4.639 | 159 | 4.798 | - | 1.526 | 420 | 1.890 | 550 | 233 | 1.178 | - | 1.155 | 0 | 0 | 233 | 100 | -525 | 0 | 233 | 100 | -348 | -23 | -420 | 0 | -735 | -39 | 573 |
| | សរុប ក | 37.436 | 12.173 | 49.609 | 1.420 | 8.104 | 2.682 | 10.574 | 6.802 | 2.161 | 7.833 | 2.304 | 9.049 | -684 | -1 | 1.737 | 410 | 853 | 59 | 741 | 52 | -270 | -3 | -378 | -14 | -1.525 | -14 | 5.587 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 79.361 | 114.727 | 194.088 | 5.300 | 22.200 | 5.100 | 21.200 | 3.653 | 7.100 | 27.100 | 6.900 | 26.300 | 0 | 0 | 2.700 | 61 | 2.500 | 57 | 1800 | 34 | 4.900 | 22 | 1.800 | 35 | 5.100 | 24 | 4.453 |
| | សរុបI=ក+ខ | 116.797 | 126.901 | 243.698 | 6.720 | 30.304 | 7.782 | 31.774 | 10.455 | 9.261 | 34.933 | 9.204 | 35.349 | -684 | 0 | 4.437 | 92 | 3.353 | 57 | 2541 | 38 | 4.630 | 15 | 1.422 | 18 | 3.575 | 11 | 10.040 |
| | II. កៅស៊ូគ្រួសារ | 133.269 | 27.834 | 161.103 | 7.700 | 32.300 | 7.500 | 31.700 | 7.076 | 9.700 | 37.300 | 9.400 | 36.400 | 0 | 0 | 3.700 | 62 | 3.500 | 59 | 2000 | 26 | 5.000 | 15 | 1.900 | 25 | 4.700 | 15 | 7.976 |
| | សរុបរួមI+II | 250.066 | 154.735 | 404.801 | 14.420 | 62.604 | 15.282 | 63.474 | 17.531 | 18.961 | 72.233 | 18.604 | 71.749 | -684 | 0 | 8.137 | 75 | 6.853 | 58 | 4541 | 31 | 9.630 | 15 | 3.322 | 22 | 8.275 | 13 | 18.016 |

បញ្ជាក់៖

(១) ផ្ទៃដីសរុបមានចំនួន ៤០៤ ៨០១ ហត ( ផ្ទៃដីចៀរជ័រ ២៥០ ០៦៦ ហត ថែទាំ ១៥៤ ៧៣៥ហត) ។

(២) ផលិតផលសរុបចំនួន ១៨ ៩៦១ តោន បានកើនឡើងចំនួន ៨ ១៣៧ តោន ( ៧៥%) ធៀបនឹងខែមុននឹងបានកើនឡើង៤ ៥៤១(៣១%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៣) រហូតមកដល់ខែមេសា ឆ្នាំ២០២០ ផលិតផលសរុបចំនួន ៧២ ២៣៣ តោន បានកើន ៩ ៦៣០តោន ( ១៥%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៤) ការបញ្ចេញលក់សរុប ១៨ ៦០៤តោន បានកើនឡើងចំនួន ៦ ៨៥៣ តោន (៥៨%)ធៀបនឹងខែមុននឹងបានកើនឡើង៣ ៣២២(២២%)ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៥) រហូតមកដល់ខែមេសា ឆ្នាំ២០២០ ការបញ្ចេញលក់សរុប ៧១ ៧៤៩តោន បានកើនឡើងចំនួន៨ ២៧៥ តោន (១៣%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៦)សន្និធិចុងគ្រាមានចំនួន១៨ ០២០ តោន

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

ចាន់_វឌ្ឍនា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

ឃួន_ផល្លា

ថ្ងៃទី ពុធ ១រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២០
អ្នកធ្វើតារាង

ហួង ស្រីស័ង